00304271

**Declassified to Public**
**06 September 2012**

E48

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

**ឯកសារដើម**
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 10 / 04 / 2009
ម៉ោង (Time/Heure): 15:30
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: UCH ARUN

**អង្គជំនុំជម្រះសាលាដំបូង**
Trial Chamber
Chambre de première instance

សំណុំរឿងលេខ:០០១/១៨ កក្កដា ឆ្នាំ ២០០៧-អវតក/អជសដ
Case File/Dossier N° 001/18-07-2007-ECCC/TC

**ចំពោះមុខ** ចៅក្រម **និល ណុន** ជាប្រធាន
ចៅក្រម **Silvia CARTWRIGHT**
ចៅក្រម **យ៉ា សុខន**
ចៅក្រម **Jean-Marc LAVERGNE**
ចៅក្រម **ធូ មុណី**

**ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម**
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification): 10 / 04 / 2009
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: UCH ARUN

កាលបរិច្ឆេទ ថ្ងៃទី ១០ ខែមេសា ឆ្នាំ ២០០៩

ប្រភេទឯកសារ សម្ងាត់

---

# ដីកាសម្រេចកំណត់កាលវិភាគសវនាការនៅតាម អង្គហេតុសម្រាប់ថ្ងៃទី ២០ ដល់ថ្ងៃទី ៣០ ខែមេសា ឆ្នាំ ២០០៩

---

**សហព្រះរាជអាជ្ញា**
ជា លាង
Robert PETIT

**ជនជាប់ចោទ**
កាំង ហ្គេកអ៊ាវ ហៅ ឌុច

**មេធាវីដើមបណ្តឹងរដ្ឋប្បវេណី**
គង់ ពិសី
ហុង គឹមសួន
យុង ផានិត
Pierre Olivier SUR
Alain WERNER
Brianne McGONIGLE
Annie DELAHAIE

**មេធាវីជនជាប់ចោទ**
ការ សាវុធ
François ROUX

TRIAL CHAMBER CHAMBRE DE PREMIÈRE INSTANCE
E C C C * E T C C

00304272

E48

001/18-07-2007-ECCC/TC

គឹម ម៉េងឃី
មុំច សុវណ្ណារី
Silke STUDZINSKY
Martine JACQUIN

Philippe CANNONE
ទី ស្រីនណា
Elizabeth RABESANDRATANA
Karim KHAN

យើង **និល ណុន** ប្រធាននៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា។

**ក្រោយពីបានទទួល** សំណុំរឿងលេខ ០០១/១៨-០៧-២០០៧-អវតក/អជសង តាមសាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនិងដីកាបញ្ជូនរឿងទៅជំនុំជម្រះលើករណីរបស់ **កាំង ហ្គេកអ៊ាវ** ហៅ ឌុច ដែលអង្គបុរេជំនុំជម្រះបានសម្រេច និងប្រកាសនៅថ្ងៃទី ០៥ ខែ ធ្នូ ឆ្នាំ ២០០៨ និងបញ្ចូលសេចក្តីសម្រេចនេះជាភាសាខ្មែរទៅក្នុងសំណុំរឿងនៅថ្ងៃទី ០៩ ខែ ធ្នូ ឆ្នាំ ២០០៨ (“សេចក្តីសម្រេច”) ។

**បានឃើញ** ដីកាសម្រេចកំណត់កាលបរិច្ឆេទចាប់ផ្តើមសវនាការលើអង្គសេចក្តី និងថ្ងៃជំនុំជម្រះសម្រាប់រយៈពេលបីខែដំបូងចុះថ្ងៃទី ២៣ ខែកុម្ភៈ ឆ្នាំ ២០០៩[1]។

**បានឃើញ** សេចក្តីណែនាំស្តីពីកម្មវិធីជំនុំជម្រះរបស់អង្គជំនុំជម្រះសាលាដំបូងចុះថ្ងៃទី ២០ ខែមីនា ឆ្នាំ ២០០៩[2]។

**បានឃើញ** សេចក្តីសម្រេចលើសំណើសុំវិធានការការពារសាក្សី និងអ្នកជំនាញ និងសំណើរបស់ភាគី ស្តាប់ចម្លើយសាក្សី និងអ្នកជំនាញ (សង្ខេប) ចុះថ្ងៃទី ០៣ ខែមេសា ឆ្នាំ ២០០៩[3]។

**រំលឹកឡើងវិញថា** សវនាការលើអង្គសេចក្តីបានចាប់ផ្តើមកាលពីថ្ងៃទី ៣០ ខែមីនា ឆ្នាំ២០០៩។

**ដោយពិចារណាអំពី** ភាពចាំបាច់ក្នុងការជូនដំណឹងអោយបានគ្រប់គ្រាន់អំពីកាលបរិច្ឆេទសវនាការដល់ភាគីទាំងអស់ ក៏ដូចជាសាក្សី និងអ្នកជំនាញដែលត្រូវធ្វើសក្ខីកម្ម។

**ហេតុដូច្នេះ**

**សម្រេច** កំណត់កាលវិភាគសវនាការលើអង្គសេចក្តីសម្រាប់ថ្ងៃទី ២០ ដល់ថ្ងៃទី ៣០ ខែមេសា ឆ្នាំ ២០០៩ ចំពោះអង្គហេតុមួយចំនួនដូចខាងក្រោម៖

TRIAL CHAMBER CHAMBRE DE PREMIERE INSTANCE
E C C C - E T C

[1] មើលឯកសារ E15

[2] មើលឯកសារ E26

[3] មើលឯកសារ E40

**- អង្គហេតុ ម ១៣ និងការបង្កើតមន្ទីរ ស ២១ និងគុកតាខ្មៅ៖** ៖ ចាប់ផ្ដើមពីថ្ងៃទី ២០ ដល់ថ្ងៃទី ២៣ ខែមេសា ឆ្នាំ ២០០៩។ ក្នុងអំឡុងពេលនេះគឺមានការសួរសំណួរទៅសាក្សី ចាន់ វឿន (KW-31) និង ចាន់ ខន (KW-32) ចំពោះអង្គហេតុ ម១៣ និងការសួរសំណួរទៅជនជាប់ចោទចំពោះអង្គហេតុនៃការបង្កើតមន្ទីរ ស ២១ និងគុកតាខ្មៅ។

**- ការអនុវត្តន៍គោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជានៅមន្ទីរ ស ២១៖** ចាប់ផ្ដើមធ្វើពីថ្ងៃទី ២៧ ដល់ថ្ងៃទី ៣០ ខែមេសា ឆ្នាំ ២០០៩។ ក្នុងអំឡុងពេលនេះមានការសួរសំណួរទៅជនជាប់ចោទ និងអ្នកជំនាញ Craig Etcheson (KW-02) និង Raoul Marc Jennar (D12)។

អង្គជំនុំជម្រះសាលាដំបូងសូមរក្សាសិទ្ធិក្នុងការកែប្រែកាលវិភាគនេះក្នុងករណីចាំបាច់។

ដីកាកំណត់កាលវិភាគបន្តបន្ទាប់ទៀតនៃដំណើរការនីតិវិធី អង្គជំនុំជម្រះនឹងកំណត់នៅពេលសមស្រប។

ភ្នំពេញ ថ្ងៃទី ១០ ខែ មេសា ឆ្នាំ ២០០៩

**ប្រធានអង្គជំនុំជម្រះសាលាដំបូង**

TRIAL CHAMBER CHAMBRE DE PREMIÈRE INSTANCE E C C C T C

**និល ណុន**